**MEDIA ADVISORY**

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីប្រកាសរួមរបស់ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) និង អង្គការពលកម្មអន្តរជាតិ (អង្គការ ILO) ស្តីពីការដោះលែងអ្នកទាំង ២៥ នាក់ដែលត្រូវបានចាប់ខ្លួននៅខែវិច្ឆិកា ឆ្នាំ ២០១៣ និង ខែ មករា ឆ្នាំ ២០១៤

ភ្នំពេញ - ការិយាល័យឧត្តមស្នងការរបស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (ការិយាល័យ OHCHR) និង អង្គការពលកម្មអន្តរជាតិ (អង្គការ ILO) ប្រចាំប្រទេសថៃ កម្ពុជា និង ឡាវ សូមស្វាគមន៍ចំពោះការដោះលែងបុរស និង កុមារាចំនួន ២៥ នៅថ្ងៃនេះ ដែលអ្នកទាំងនេះត្រូវបានចាប់ខ្លួន និង បើកសវនាការជំនុំជម្រះ បន្ទាប់ពីមានការតវ៉ារបស់កម្មករ និង ការបង្ក្រាបបណ្តាលឲ្យស្លាប់កម្មករពីកងកម្លាំងសន្តិសុខនៅស្ទឹងមានជ័យនៅថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៣ និង នៅក្បែររោងចក្រយ៉ាកជីង និង សួនឧស្សាហកម្មកាណាឌីយ៉ា នៅថ្ងៃទី ២ និង ៣ ខែ មករា ឆ្នាំ ២០១៤។ នីតិជន និង អនីតិជនទាំង ២៥ នាក់ ដែលត្រូវបានតុលាការបើកសវនាការជំនុំជម្រះក្នុងសវនាការបីដាច់ដោយឡែកពីគ្នា ត្រូវបានរកឃើញថាមានទោសដោយសាលាដំបូងរាជធានីភ្នំពេញ កាលពីព្រឹកមិញនេះ ពីបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ បទហិង្សាដោយចេតនាដោយមានស្ថានទម្ងន់ទោស និង បទបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយចេតនា ហើយបានសម្រេចផ្តន្ទាទោសឲ្យជាប់ពន្ធនាគារចន្លោះប្រាំមួយខែ និង បួនឆ្នាំកន្លះ។ គ្រប់រឿងក្តីទាំងអស់នេះ ត្រូវបានសម្រេចព្យួរទោស ហើយឥឡូវនេះ អ្នកទាំង២៥នាក់នេះត្រូវបានដោះលែងឲ្យមានសេរីភាពដោយ អ្នកទាំង ២២ នាក់ ដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន ត្រូវបានដោះលែងនៅព្រឹកនេះ។

ការិយាល័យ OHCHR និង អង្គការ ILO មានការព្រួយបារម្ភពីការផ្តន្ទាទោសអ្នកទាំង ២៥ ចំពោះកង្វះខាតនីតិវិធីយ៉ាងច្បាស់នៅក្នុងសវនាការជម្រះក្តីទាំងបី និង កង្វះ

**Office of the High Commissioner for Human Rights**
Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org
For further information, visit: www.cambodia.ohchr.org

# MEDIA ADVISORY

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

ភស្តុតាង ដែលបង្កើតឲ្យមានការទទួលខុសត្រូវដោយផ្ទាល់ចំពោះសកម្មភាពរបស់អ្នកទាំងនោះដែលត្រូវបានចាប់ខ្លួន នៅពេលអនុវត្តសិទ្ធិជាមូលដ្ឋានក្នុងការសម្តែងមតិ និង ជួបជុំដោយសន្តិវិធី ក្នុងខណៈពេលការពារផលប្រយោជន៍សង្គម សេដ្ឋកិច្ចរបស់កម្មករ។

ការិយាល័យ OHCHR និង អង្គការ ILO សូមធ្វើការអំពាវនាវជាថ្មីម្តងទៀតឲ្យមានការស៊ើបអង្កេតដោយឯករាជ្យ និង ការទទួលខុសត្រូវពេញលេញចំពោះការបំបែកដោយហិង្សាលើបាតុកម្មនៅថ្ងៃទី ១២ ខែ វិច្ឆិកា និង នៅថ្ងៃទី ២ និង ៣ ខែ មករា។ ការប្រឈមនេះបណ្តាលឲ្យមានការបាញ់សម្លាប់មនុស្សប្រាំនាក់ ការស្លាប់មនុស្សទីប្រាំមួយដែលស្លាប់ពេលក្រោយដោយសាររបួសពីការវាយដំ ការបាត់ខ្លួនមនុស្សម្នាក់ និងរងរបួសជាច្រើនពីការប្រើប្រាស់គ្រាប់ពិត និង ការវាយដំ រួមទាំងអ្នកមើលហេតុការណ៍ម្នាក់ធ្លាក់ខ្លួនពិការមកដល់ពេលនេះ។ បុគ្គលទាំងឡាយគួរតែអាចអនុវត្តសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និង ជួបជុំដោយសន្តិវិធី ក្នុងបរិយាកាសគ្មានហិង្សា ការភ័យខ្លាច ឬ គម្រាមកំហែងគ្រប់ប្រភេទ។

បញ្ចប់

*ភ្នំពេញ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង Bushra Rahman ការិយាល័យ OHCHR កម្ពុជា តាម Tel +855 012 790 178 / email: brahman@ohchr.org*

**Office of the High Commissioner for Human Rights**
Tel: + (855-23) 993 590
Fax + (855-23) 212 579
Email: cambodia@ohchr.org
For further information, visit: www.cambodia.ohchr.org